## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៥៧១ សសរ.កសក

## សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងមន្ត្រីបង្គោលថ្នាក់ជាតិ
## អនុវត្តអនុសញ្ញារ៉ូតើដាម

### រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩១២/០០៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញារ៉ូតើដាម ស្តីពីនីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុនចំពោះសារធាតុគីមី និងថ្នាំកសិកម្មគ្រោះថ្នាក់ក្នុងពាណិជ្ជកម្មអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្ម ឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax : (855) 23 - 217 320

## សម្រេច

**ប្រការ១ .-**

ត្រូវបានតែងតាំងមន្ត្រីបង្គោលថ្នាក់ជាតិអនុវត្តអនុសញ្ញារ៉ូថឺដាម (RC OCP) ស្តីពីនីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុនចំពោះសារធាតុគីមីនិងថ្នាំកសិកម្មគ្រោះថ្នាក់ក្នុងពាណិជ្ជកម្មអន្តរជាតិ ដើម្បីទទួលបន្ទុកដឹកនាំនិងអនុវត្តនៅរាល់ភារកិច្ចពាក់ព័ន្ធ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបំពេញតួនាទីជាសមាជិកនៃអនុសញ្ញានេះដែលមានសមាសភាពដូចខាងក្រោមៈ

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឡោ រស្មី** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ | ប្រធាន |
| ២-លោក | **ម៉ាន ណារិនី** | អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ | អនុប្រធាន |
| ៣-លោក | **គុំ រ៉ា** | ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម | អនុប្រធាន |
| ៤-លោក | **កែ មុន្នីខុន** | ប្រធាននាយកដ្ឋានការពារដំណាំ អនាម័យនិងភូតគាមអនាម័យនៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិក |
| ៥-លោក | **ម៉ុក គឹមស្រួយ** | ប្រធាននាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្មនៃអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ | សមាជិក |
| ៦-លោក | **សេខ ម៉ាខ** | នាយករងវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា | សមាជិក |
| ៧-លោកស្រី | **មិនិន ម៉ារីណែត** | អនុប្រធានការិយាល័យនៃនាយកដ្ឋាននីតិកម្មកសិកម្ម | លេខាធិការ។ |

**ប្រការ២ .-**

មន្ត្រីបង្គោលថ្នាក់ជាតិ (Oficial Contact Point) បំពេញមុខងារដូចខាងក្រោម៖

- ទំនាក់ទំនងនិងសម្របសម្រួលជាទៀងទាត់ផ្នែករដ្ឋបាលជាមួយលេខាធិការដ្ឋាននៃអនុសញ្ញារ៉ូថឺដាម តាមការតម្រូវនៃអនុសញ្ញារ៉ូថឺដាម
- ទទួលការជូនដំណឹងស្តីពីការចូលរួមកិច្ចប្រជុំសន្និបាតភាគី (Conference of the Parties)
- ទំនាក់ទំនងនិងសម្របសម្រួលជាមួយស្ថាប័នជាតិពាក់ព័ន្ធនិងរដ្ឋជាសមាជិកនៃអនុសញ្ញានូវរាល់ភារកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងដំណើរការអនុវត្តអនុសញ្ញារ៉ូថឺដាម
- ចរាចរឯកសាររបាយការណ៍នៃកិច្ចប្រជុំសន្និបាតភាគី ឬកិច្ចប្រជុំពាក់ព័ន្ធជូនដល់ស្ថាប័នជាតិពាក់ព័ន្ធ
- កាតព្វកិច្ចក្នុងការធ្វើសំណើសម្រាប់ការបំពេញបន្ថែមនូវសារធាតុគីមីកសិកម្មឬថ្នាំកសិកម្មគ្រោះថ្នាក់ ដែលពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មទៅក្នុងឧបសម្ព័ន្ធទី៣ នៃអនុសញ្ញារ៉ូថឺដាម
- បរិយាប័ន្ននីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុន (Inclusive in the PIC procedure) ចំពោះសារធាតុគីមីនិងថ្នាំកសិកម្មគ្រោះថ្នាក់ក្នុងពាណិជ្ជកម្មអន្តរជាតិ តាមការតម្រូវរបស់លេខាធិការដ្ឋាននៃអនុសញ្ញារ៉ូថឺដាម
- មានកាតព្វកិច្ចក្នុងការចាត់បញ្ជូនអ្នកជំនាញឬមន្ត្រីជំនាញទៅក្នុងគណៈកម្មការត្រួតពិនិត្យសារធាតុគីមីនៃលេខាធិការដ្ឋានអនុសញ្ញារ៉ូថឺដាមនិងសម្របសម្រួលភារកិច្ចផ្សេងៗទៀតតាមការជាក់ស្តែង
- ដឹកនាំនិងសម្របសម្រួលអង្គប្រជុំនៃអាជ្ញាធរជាតិ ដោយអញ្ជើញតំណាងស្ថាប័នជាតិពាក់ព័ន្ធ ឬអង្គភាពជំនាញពាក់ព័ន្ធតាមការចាំបាច់ ដើម្បីពិភាក្សាវាយតម្លៃលើប្រភេទសារធាតុគីមីកសិកម្ម ឬថ្នាំកសិកម្មដែលមានសក្តានុពលបង្កគ្រោះថ្នាក់ ឬមានហានិភ័យខ្ពស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- សម្របសម្រួលក្នុងការបង់ប្រាក់វិភាគទានសមាជិកភាពរបស់ព្រះរាជាណាចក្រកម្ពុជា ស្របតាមការតម្រូវរបស់លេខាធិការដ្ឋាននៃអនុសញ្ញា។

**ប្រការ៣ .-**

មន្ត្រីបង្គោលថ្នាក់ជាតិ មានអាជ្ញាធរជាតិអនុវត្តអនុសញ្ញារ៉ូថឺដាម (Rotterdam Convention Designated Natioanl Authority/RC DNA) ដែលបំពេញមុខងារជាជំនួយការឲ្យមន្ត្រីបង្គោលថ្នាក់ជាតិ ដើម្បីអនុវត្តនូវកាតព្វកិច្ចការ

ទំនាក់ទំនង និងសម្របសម្រួលលើរាល់ភារកិច្ចរបស់លេខាធិការដ្ឋាននៃអនុសញ្ញារ៉ូថឺដាម ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-លោក | **ម៉ុច ចន្ថា** | អនុប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម | ប្រធាន |
| ២-លោក | **ហេង ឈុនហ៊ី** | អនុប្រធាននាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យនៃអគ្គនាយកដ្ឋានកសិកម្ម | អនុប្រធាន |
| ៣-លោក | **មេ សៀកម៉េង** | អនុប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម | អនុប្រធាន |
| ៤-លោក | **រ៉ានី ធីរៈ** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៥-លោក | **តាង ជិនថេង** | អនុប្រធានមន្ទីរពិសោធន៍ជាតិកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិក |
| ៦-លោក | **ជា សុខុន** | អនុប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម | សមាជិក |
| ៧-លោក | **ឡោ វ៉ាន់ណុល** | ប្រធានការិយាល័យនៃនាយកដ្ឋាននីតិកម្មកសិកម្ម | សមាជិក |
| ៨-លោក | **ស៊ិន សាខុទ្ធ** | ប្រធានការិយាល័យនៃនាយកដ្ឋាននីតិកម្មកសិកម្ម | សមាជិក |
| ៩-លោក | **សែន សុជាតិ** | មន្ត្រីការិយាល័យនៃនាយកដ្ឋាននីតិកម្មកសិកម្ម | លេខាធិការ។ |

**ប្រការ៤ .-**

អាជ្ញាធរជាតិអនុវត្តអនុសញ្ញារ៉ូថឺដាម ត្រូវបំពេញមុខងារដ៏សំខាន់ពាក់ព័ន្ធទៅនឹងដំណើរការអនុវត្តអនុសញ្ញាសម្រាប់បណ្តាភាគីពាក់ព័ន្ធ និងលេខាធិការដ្ឋាននៃអនុសញ្ញារ៉ូថឺដាម ក្នុងនោះមាន៖

១-តួនាទីក្នុងការផ្សព្វផ្សាយនិងចែកចាយព័ត៌មានពាក់ព័ន្ធទៅនឹងបទប្បញ្ញត្តិនៃអនុសញ្ញាទៅនឹងស្ថាប័នជំនាញពាក់ព័ន្ធរបស់រដ្ឋាភិបាល ក៏ដូចជាដៃគូពាក់ព័ន្ធផ្សេងៗ ដូចជា បណ្តាប្រទេសឧស្សាហកម្មនាំចេញ-នាំចូល និងមន្ត្រីគយប្រចាំការ។

២-ទទួលខុសត្រូវក្នុងការផ្តល់ព័ត៌មានទៅលេខាធិការដ្ឋាននៃអនុសញ្ញារ៉ូថឺដាមនិងបណ្តាប្រទេសចូលរួមផ្សេងទៀត តាមការតម្រូវដោយអនុសញ្ញា។

៣-បង្កើតក្រុមការងារបច្ចេកទេសដែលជ្រើសរើសចេញពីសមាជិកអាជ្ញាធរជាតិ និងរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនដើម្បីបំពេញមុខងារអចិន្ត្រៃយ៍លើរាល់ភារកិច្ចរបស់អាជ្ញាធរជាតិអនុវត្តអនុសញ្ញារ៉ូថឺដាមប្រព្រឹត្តទៅប្រកបដោយភាពរលូន និងមានសិទ្ធិប្រើប្រាស់មន្ត្រីរាជការនៃនាយកដ្ឋាននីតិកម្មកសិកម្មដោយផ្ទាល់ ឬអាចលើកសំណើតាមរយៈមន្ត្រីបង្គោលថ្នាក់ជាតិជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាបន្ថែមតាមតម្រូវការចាំបាច់។

៤-ទទួលខុសត្រូវនូវភារកិច្ចផ្សេងៗទៀតដូចតទៅ៖

- ការជូនដំណឹងទៅលេខាធិការដ្ឋានអំពីវិធានការច្បាប់ចុងក្រោយបង្អស់ (Final regulation action) ចំពោះការហាមឃាត់ ឬ ដាក់លក្ខខណ្ឌចំពោះសារធាតុគីមីណាមួយ
- ការពិនិត្យវាយតម្លៃ និងបញ្ជូនសំណើស្តីពីផលិតផលថ្នាំកសិកម្មលាយផ្សំគ្រោះថ្នាក់ខ្ពស់ (Severly hazardous pesticide formulations)
- ផ្តល់នូវការឆ្លើយតបចំពោះការនាំចូលសារធាតុគីមី (Import responses) ដែលជាកម្មវត្ថុនៃការអនុវត្តនីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុន
- ទំនាក់ទំនងក្នុងការឆ្លើយតបចំពោះការនាំចូលសារធាតុគីមីដល់ស្ថាប័នជាតិនិងផ្នែកពាក់ព័ន្ធទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ការពិនិត្យនិងឆ្លើយតបពីការទទួលស្គាល់នូវសេចក្តីជូនដំណឹងអំពីការនាំចេញ (Export notification)
- ការផ្លាស់ប្តូរព័ត៌មានរវាងលេខាធិការដ្ឋាននៃអនុសញ្ញារ៉ូថឺដាម បណ្តាប្រទេសភាគី និងស្ថាប័នជាតិនិងផ្នែកពាក់ព័ន្ធទាំងអស់ ។

- សិក្សា និងវាយតម្លៃលើប្រភេទសារធាតុគីមីកសិកម្ម ឬថ្នាំកសិកម្ម ដែលមានសក្តានុពល បង្កគ្រោះថ្នាក់ ឬមានហានិភ័យខ្ពស់ តាមការស្នើសុំរបស់គណៈកម្មការសារធាតុគីមីនៃអនុសញ្ញារ៉ូថឺដាម ដើម្បីសម្រេចបញ្ចូលក្នុងឧបសម្ព័ន្ធទី៣នៃអនុសញ្ញា
- តាមដានការអនុវត្តអនុសញ្ញារ៉ូថឺដាមរបស់រដ្ឋជាសមាជិកផ្សេងៗទៀតដែលជាប្រទេសមានប្រភពដើមផលិត ឬនាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអាចធ្វើប្រតិកម្មតវ៉ាចំពោះករណីមិនអនុលោមតាមបទប្បញ្ញត្តិរបស់អនុសញ្ញានៅក្នុងការអនុវត្តរបស់រដ្ឋជាសមាជិកណាមួយ
- តាមដាន ត្រួតពិនិត្យ ប្រមូលផ្តុំចងក្រងនូវរបាយការណ៍ព័ត៌មានស្តីពីគ្រោះថ្នាក់ដែលបង្កដោយប្រភេទសារធាតុគីមីកសិកម្ម ឬថ្នាំកសិកម្ម ដែលត្រូវបានធ្វើពាណិជ្ជកម្មនិងប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ពង្រឹងសមត្ថភាពសមាជិកក្រុមការងារបច្ចេកទេសរបស់អាជ្ញាធរជាតិ ដើម្បីបំពេញមុខងារអចិន្ត្រៃយ៍លើរាល់ភារកិច្ចរបស់អាជ្ញាធរជាតិអនុវត្តអនុសញ្ញារ៉ូថឺដាម និងធ្វើការផ្សព្វផ្សាយជូនពាណិជ្ជករ អាជីវករនូវសារធាតុគីមីកសិកម្ម ឬថ្នាំកសិកម្ម ស្តីពីកាតព្វកិច្ចអនុវត្តអនុសញ្ញារ៉ូថឺដាម នៅក្នុងការធ្វើពាណិជ្ជកម្មអន្តរជាតិ
- ធ្វើរបាយការណ៍ ឬជូនព័ត៌មាន ឬបំពេញបែបបទរបស់អនុសញ្ញា ដែលពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មសារធាតុគីមីកសិកម្ម ឬថ្នាំកសិកម្មគ្រោះថ្នាក់ តាមការតម្រូវរបស់លេខាធិការដ្ឋាននៃអនុសញ្ញារ៉ូថឺដាម
- បំពេញភារកិច្ចផ្សេងទៀតតាមការតម្រូវរបស់លេខាធិការដ្ឋាននៃអនុសញ្ញារ៉ូថឺដាម ឬតាមការប្រគល់ជូនរបស់មន្ត្រីបង្គោលថ្នាក់ជាតិ។

**ប្រការ៥ .-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

អគ្គលេខាធិការ អគ្គាធិការ ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធានអង្គភាពពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៣រោច ខែ មិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ដូចប្រការ ៦
- ឯកសារ កាលប្បវត្តិ